# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**KINGDOM OF CAMBODIA**

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

**Ministry of Commerce**

No. ០៧ MOC / M 2004

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៤

## ប្រកាស

### ស្តីពីការផ្តល់វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ (Certificate of Origin) ជូនសិប្បកម្មក្នុងស្រុក

### រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្របក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ ក្រសួងពាណិជ្ជកម្ម
- ក្នុងគោលបំណងបង្កើនសន្ទុះនាំចេញផលិតផលក្នុងស្រុក និង ដើម្បីជួយសំរួលបែបបទនាំចេញផលិតផលសិប្បកម្មផ្សេងៗ ធ្វើអំពីសូត្រ , អំបោះ , ដែក , ថ្មៅ , កំប្លោក , ស្លឹកត្នោត , គ្រឿងចម្លាក់សម័យទំនើប វត្ថុប្រើប្រាស់បន្ទាប់បន្សំ ។ល។ ឱ្យបានឆាប់រហ័ស

## សំរេច

**ប្រការ ១ :** ដើម្បីអោយសិប្បកម្មក្នុងស្រុកមានសិទ្ធិ ទទួលបាននូវវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ (Certificate of Origin) ពីក្រសួងពាណិជ្ជកម្មសំរាប់នាំទំនិញសិប្បកម្មរបស់ខ្លួនទៅបរទេសបាន សិប្បកម្មនោះត្រូវចុះបញ្ជីនៅនាយកដ្ឋាន ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម (ដោយមានភ្ជាប់វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជករ និងក្រុមហ៊ុន របស់នាយកដ្ឋាននីតិកម្ម) ដើម្បីទទួលបានសិទ្ធិនាំចេញតាមរយៈប្រព័ន្ធ MFN/GSP (លើកលែងផលិតផល ជាប់កូតា) ។

**ប្រការ ២ :** ក្នុងករណីផលិតផលនាំចេញមិនជាប់កូតា ការចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញនេះ (C/O) ត្រូវបានលើកទឹកចិត្តជូនដោយមិនមានតម្រូវឱ្យ បង់កំរៃ ឬ សោហ៊ុយរដ្ឋបាលអ្វីឡើយ ។

**ប្រការ ៣ :** នាយកខុទ្ទកាល័យ , អគ្គនាយកបច្ចេកទេស , អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ , ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋាននីតិកម្ម , ប្រធាននាយកដ្ឋានកាំកុងត្រូល , ប្រធាននាយកដ្ឋានរដ្ឋបាល ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាព ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**ចម្លងជូន :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
- អគ្គនាយកដ្ឋានបច្ចេកទេស
- នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស
- នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម
- នាយកដ្ឋានជំរុញការនាំចេញ
- នាយកដ្ឋាននីតិកម្ម
- នាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស

" ដើម្បីអនុវត្ត "

- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

Prakas on the status of C/O issuance for handicraft.doc